វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ព្រះរាជក្រឹត្យនស/រកត/០១៩៩/០៧

ថ្ងៃទី ១១ ខែ មករាឆ្នាំ ១៩៩៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និតរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី ១១ ធ្នូ ឆ្នាំ១៩៩៨

**ត្រាស់បង្គាប់**

មាត្រា ១ :

ត្រូវបានបង្កើតអោយមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ :

ដីជំរាលជាជួរនៃតំបន់ដីខ្ពស់ ដែលផ្នែកសងខាងនៃតំបន់នោះ មានចរន្តទឹកហូរចាត់ទៅក្នុងអូរ ស្ទឹង បឹង ទន្លេ ឬ សមុទ្រ ។

មាត្រា ៣:

កំណត់ និងគ្រប់គ្រងព្រៃឈើតំបន់ដីជំរាលក្នុងគោលបំណង :

ក- ការពារការហូរច្រោះ

ខ-កាត់បន្ថយល្បឿនចរន្តទឹកក្នុងតំបន់ដីជំរាល

គ-រក្សា និយ័តភាពប្រភពទឹកក្នុងដី

ឃ-ទប់ទល់ការបាត់បងជីវជាតិរបស់ដី

ង-រក្សានូវសុក្រឹតភាព នៃប្រភព និងគុណភាពទឹក

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ច-គាំពារជីវចំរុះ

ឆ-ធ្វើអោយមានលំនឹងដល់បរិស្ថានធម្មជាតិ

មាត្រា ៤ :

កំណត់ផ្ទៃដីព្រៃឈើតំបន់ដីជំរាល ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥:

ផ្ទៃដី ព្រៃឈើក្នុងតំបន់ដីជំរាលអាច នឹងកែប្រែពង្រីងបន្ថែម ដោយផ្អែកទៅលើពតិមានវិទ្យាសាស្ត្រ និងស្ថានភាពជាក់ស្តែងនៅពេលអនាគត ។

មាត្រា ៦ :

ការអភិវឌ្ឍន៍ ការធ្វើអាជីវកម្មផល អនុផលព្រៃឈើគ្រប់ប្រភេទនៅតំបនដិជំរាលត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧ :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រង និងធ្វើការអភិវឌ្ឍន៍ ព្រៃឈើតំបន់ដីជំរាលដូចចែងក្នុងអាត្រា២ ហើយមានសិទ្ធិធ្វើសហត្រិបត្តិការជាមួយអន្តរក្រសួង អង្គការអន្តរជាតិ ឬ អង្គការក្រៅរដ្ឋាលភិបាល លើបន្ទាត់នយោបាយព្រៃឈើ និងបច្ចេទេស ។

មាត្រា៨ :

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៩:

ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។